00194531

**Declassified to Public**
**06 September 2012**

ឯកសារលេខ: D25/6/10

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / 05 / 2008
ម៉ោង (Time/Heure): 15:05
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ក្រឡាបញ្ជីនៃសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ជម្រាបមក

**ឈ្មោះ៖** ជុំ ស៊ីវ៉ាត

**អាសយដ្ឋាន៖** មេធាវី យុង ផានិត និង **Silke STUDZINSKY** គម្រោងការពារសិទ្ធិកម្ពុជា ផ្ទះលេខ ១២ ផ្លូវលេខ ២៨២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

**អ៊ីម៉ែល៖** phanit@cdpcambodia.org និង silke.studzinsky@ded-cambodia.org

**ថ្ងៃទទួលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត៖**
ថ្ងៃសុក្រ ទី ២៣ ខែឧសភា ឆ្នាំ ២០០៨

**សំណុំរឿងព្រហ្មទណ្ឌលេខ៖** ០០១/១៨-០៧-២០០៧-ECCC-OCIJ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

**កម្មវត្ថុ៖ ស្ថានភាពនៃការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ទំរង់បែបបទសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ត្រូវបានទទួលដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត នៅថ្ងៃខែឆ្នាំខាងលើ ហើយ តាមការណែនាំរបស់លោកសហចៅក្រមស៊ើបអង្កេត ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖ ០០១/១៨-០៧-២០០៧-ECCC-OCIJ នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៨។ ដូច្នេះ លើកលែងតែមានសេចក្តីសម្រេចផ្លាស់ប្តូរនៅពេលក្រោយរបស់សហចៅក្រមស៊ើបអង្កេត (សូមអានកឋាខ័ណ្ឌទី ២) លោកនៅពេលនេះ ត្រូវបានចាត់ទុកជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងដំណើរការស៊ើបអង្កេតរបស់តុលាការទាក់ទិននឹងរឿងក្តីនេះ។

សូមរំលឹកថា នៅគ្រប់ពេលនៃដំណើរការស៊ើបអង្កេតរបស់ខ្លួន សហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្តីសម្រេចផ្លូវការមួយទាក់ទិននឹងពាក្យសុំរបស់លោក ដែលអាចជាការសម្រេចយល់ព្រម ឬបដិសេធ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាឃើញថា លោក មិនមែនជាជនរងគ្រោះ ឬថាលក្ខណៈវិនិច្ឆ័យទាំងឡាយដែលកំណត់ដោយវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្តស្តីពី

ការចូលរួមរបស់ជនរងគ្រោះ មិនត្រូវបានបំពេញ។ សេចក្តីសម្រេចបែប នេះ គឺបើកឲ្យធ្វើបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះបាន។

លោក ក៏ត្រូវដឹងផងដែរថា តាមរយៈការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី លោកអាចដឹងអំពីព័ត៌មានសម្ងាត់នានាដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌនេះ។ មានតែចៅក្រមនៃអង្គ-ជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) ប៉ុណ្ណោះ ដែលអាចសម្រេចផ្តល់ព័ត៌មានទាំងនោះជាសាធារណៈ។ លោក មានកាតព្វកិច្ចរក្សាការសម្ងាត់នៃការស៊ើបអង្កេតរបស់តុលាការ ដោយមិនត្រូវលាតត្រដាងព័ត៌មានសម្ងាត់ទាំងនេះឡើយ លើកលែងតែព័ត៌មានផ្ទាល់ខ្លួនណាដែលលោកបានផ្តល់ជូនចៅក្រមនៅក្នុងពាក្យសុំរបស់លោក។

ប្រសិនលោក ត្រូវការការណែនាំបន្ថែម ទាក់ទិននឹងការចូលរួមរបស់លោក នៅក្នុងនីតិវិធីតុលាការ សូមធ្វើទំនាក់ទំនងមកកាន់អង្គភាពគាំពារជនរងគ្រោះ។ វិធាន និងសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក. អាចពិគ្រោះ និងថតចម្លងទុកបានពីគេហទំព័រនៃអង្គភាពគាំពារជនរងគ្រោះ (www.eccc.gov.kh)។

សូមលោក ទទួលនូវការរាប់អានអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៨

ក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត

LY Chantola ឈាង ស៊ែន